វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)
CDRI
សង្ខេបសម្រាប់
គោលនយោបាយ
២០២១ លេខ ៤

# ការអនុវត្តល្អ និងមេរៀនទទួលបានពីផលិតកម្មកសិកម្ម តាមកិច្ចសន្យានៅវៀតណាម

## សារគោលនយោបាយសំខាន់ៗ

ផលិតកម្មកសិកម្មតាមកិច្ចសន្យា (CF) បានចាប់ផ្តើមជាផ្លូវការនៅប្រទេសវៀតណាមនាឆ្នាំ២០០២។ ចាប់តាំងពីពេលនោះមក គំរូទាក់ទិនមានប្រសិទ្ធភាពជាច្រើន ត្រូវបានកែលំអខាងវិស័យកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។ គំរូ CF សំខាន់ៗមាន ៤គឺ ពហុភាគី ប្រមូលផ្តុំ អចលនទ្រព្យ និង អន្តរការីនិងក្រៅផ្លូវការ។ នៅមានសំណួរថា តើគំរូណាមានអានុភាពខ្លាំងដើម្បីឱ្យពាក់ព័ន្ធ និងមានអត្ថប្រយោជន៍ដល់កសិករខ្នាតតូច។ ជាពិសេសគោលនយោបាយរដ្ឋាភិបាលត្រូវផ្តោតលើការបង្កើតបរិយាកាសជំនួញ ដល់សហគ្រាសកសិកម្ម ដែលដើរតួនាទីសំខាន់ក្នុងការគ្រប់គ្រងសង្វាក់តម្លៃ ព្រមទាំងផ្តល់ការគាំទ្រខាងហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងការអនុវត្ត CF។ គោលនយោបាយក៏ត្រូវផ្តោតលើអង្គការកសិករគោលដៅនានា ជាជាងកសិករជាបុគ្គល ខាងការកសាងសមត្ថភាពដើម្បីកែលំអអភិបាលកិច្ចនិងការទទួលបានឥណទាន និងដើម្បីឱ្យមានចីរភាពកិច្ចសន្យា សម្រាប់ទាំងអស់គ្នា។ គោលនយោបាយគាំទ្រ ដល់ភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន ក៏ដើរតួនាទីសំខាន់ដែរ និងជាវិជ្ជមានក្នុងការផ្តួចផ្តើម និងលើកតម្កើង CF ខាងផលិតកម្មកសិកម្ម និងទីផ្សារ។

## សេចក្តីផ្តើម

CF ត្រូវបានលើកតម្កើងជាវិធានការមួយ ដើម្បីសម្របសម្រួលការចូលរួមរបស់កសិករ ក្នុងផលិតកម្មកសិកម្មពាណិជ្ជកម្ម ការបន្ថែមតម្លៃឱ្យបានច្រើនដល់ផលិតផលកសិកម្ម។ ការសិក្សាសង្កេត CF ក្នុងការកំណត់ការអនុវត្តល្អៗ ទាក់ទិននឹងការប្រតិបត្តិរបស់ខ្លួននៅវៀតណាម។ លើសពីនេះ ការសិក្សាពិនិត្យ និងវិភាគ គោលនយោបាយនានាដែលទ្រទ្រង់ដល់ CF និងស្នើយោបល់ជាគោលនយោបាយសម្រាប់ការអភិវឌ្ឍនៅប្រទេសវៀតណាម។ មេរៀនទទួលបានពីការអនុវត្តល្អៗ និងសង្ខេបគោលនយោបាយ នឹងជួយដល់អង្គការអភិវឌ្ឍន៍អន្តរជាតិ សហគ្រាស អ្នកតាក់តែងគោលនយោបាយ និងអ្នកពាក់ព័ន្ធទាក់ទិននានា ក្នុងការស្វែងយល់ពីស្ថានភាពបច្ចុប្បន្ន និងឧបសគ្គនានានៃ CF នៅវៀតណាម។ ការវិភាគលើការសិក្សា នឹងរួមចំណែកជាមេរៀនដ៏សំខាន់ សម្រាប់អន្តរាគមន៍គោលនយោបាយ និងការតស៊ូមតិខាងគោលនយោបាយ មិនត្រឹមតែនៅវៀតណាម តែក៏សម្រាប់ប្រទេសផ្សេងទៀតក្នុងតំបន់ ដែល CF ជាអ្នកនាំមុខសំខាន់មួយនៃការអភិវឌ្ឍកសិកម្ម។

រូបភាព៖ អនុបាតតំបន់ក្នុងកម្មវិធីមូលដ្ឋានខ្នាតធំដែលមាន ទិញកិច្ចសន្យា (%)




## លទ្ធផលសំខាន់ៗ

CF នៅវៀតណាមមាន ៤ប្រភេទសំខាន់ៗ រួមមាន គំរូពហុភាគី គំរូប្រមូលផ្តុំ គំរូអចលនទ្រព្យ និង គំរូអន្តរការីនិងក្រៅផ្លូវការ។ គំរូពហុភាគី ទំនងជាគំរូដែលសមស្របសម្រាប់កសិករកាន់កាប់តូចៗ ឯគំរូប្រមូលផ្តុំ តែងទាក់ទិននឹងសហគ្រាសខ្នាតធំ ជាពិសេសក្រុមហ៊ុនរកស៊ីរួមគ្នា និងក្រុមហ៊ុនបរទេស និងកសិករដែលមានជីវភាពធូរធារ។ គំរូអចលនទ្រព្យ គឺជាអតីតកសិដ្ឋានរបស់រដ្ឋ ត្រូវបានធ្វើឱ្យមានសមភាព ហើយដីធ្លីត្រូវបានបែងចែកឱ្យតាមគ្រួសារនានា ដែលជាអតីតសមាជិកកសិដ្ឋាន។ គំរូអន្តរការីនិងក្រៅផ្លូវការ គឺផ្អែកលើកិច្ចសន្យាផ្ទាល់មាត់ ឬការជឿជាក់ក្នុងចំណោមដៃគូ។ ជាទូទៅ មិនមានគំរូ CF ជាក់លាក់ណាដែលសមស្របរាល់ផលិតផល ទីតាំង និងកសិករនោះទេ។ ប្រភេទ CF នីមួយៗ មានគុណសម្បត្តិ និងគុណវិបត្តិរបស់វា។

លទ្ធផលបានពីការសិក្សាទាំង ៦ករណី បង្ហាញថា ប្រសិទ្ធភាពសហគ្រាស ខាងការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស និងការត្រួតពិនិត្យ និងស្នាដៃល្អៗរបស់អង្គការកសិករ គឺជាកត្តាសំខាន់ជះឥទ្ធិពលថា តើកិច្ចសន្យានឹងទទួលបានជោគជ័យ ឬអត់សម្រាប់កសិកម្មនៅវៀតណាម។ សហគ្រាសនានា បង្ហាញពីសារៈសំខាន់របស់គេក្នុងការផ្តល់ធាតុចូលជាសម្ភារៈ គោលការណ៍បច្ចេកទេស យន្តការត្រួតពិនិត្យ ការទិញទិន្នផល និងការធានាចំណូលរបស់

រៀបចំដោយ Nguyen Anh Phong, Director of the Centre for Agriculture and Rural Development Information, Institute of Policy and Strategy for Agriculture and Rural Development (IPSARD) and Nguyen Do Anh Tuan, Director General of the International Cooperation Department, Ministry of Agriculture and Rural Development.
សូមយោងឯកសារថា៖ Nguyen Anh Phong et al. 2021. “Good Practices and Lessons Learned from Contract Farming in Vietnam.” Policy Brief. Phnom Penh: CDRI.

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១ ៣៨៤/៨៨១ ៧០១/៨៨១ ៩១៦/៨៨៣ ៦០៣
🖷 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

តារាង១៖ កត្តាជោគជ័យសំខាន់ៗសម្រាប់ CF នៅវៀតណាម

| ក្រុមហ៊ុន | កសិករ | សហគមន៍កសិករ | អ្នកពាក់ព័ន្ធសាធារណៈ (រដ្ឋាភិបាល DARD ។ល។) |
|---|---|---|---|
| - គាំទ្រកសិករទាំង ការណែនាំបច្ចេកទេស និងធាតុចូលផលិតកម្មជាមុន (ជី ថ្នាំសម្លាប់សត្វល្អិត គ្រាប់ពូជមានគុណភាពខ្ពស់)<br>- គ្រប់គ្រង និងត្រួតពិនិត្យដោយផ្ទាល់ពីការអនុវត្តដាំស្រូវរបស់កសិករ ដើម្បីធានាបាននូវស្រូវមានគុណភាពល្អ<br>- ការប្តេជ្ញាចិត្តក្នុងការទិញរាល់ផលិតផល ធានាបាននូវប្រាក់ចំណេញខ្ពស់សម្រាប់កសិករ<br>- មានទីផ្សារអតិថិជនថេរ<br>- មានសមត្ថភាពហិរញ្ញវត្ថុរឹងមាំ | - មានសមត្ថភាពល្អ (ដីចំណេះដឹងជំនាញ ។ល។) អនុលោមតាមតម្រូវការស្តង់ដាររបស់ក្រុមហ៊ុន<br>- អនុវត្តយ៉ាងតឹងរឹងផែនការផលិតកម្មតាមការកំណត់ដោយក្រុមហ៊ុន / សហករណ៍ | - គាំទ្រកសិករទាំង ការណែនាំបច្ចេកទេស និងធាតុចូលផលិតកម្មជាមុន (ជី ថ្នាំសម្លាប់សត្វល្អិត គ្រាប់ពូជមានគុណភាពខ្ពស់)<br>- មានមេដឹកនាំសកម្ម សមត្ថភាពខ្ពស់ក្នុងការគ្រប់គ្រង<br>- មានកេរ្តិ៍ឈ្មោះល្អជាមួយកសិករ<br>- មានទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធអ្នកដទៃ ដូចជា សហគ្រាស រដ្ឋាភិបាលមូលដ្ឋានជាដើម ។ល។ ដើម្បីស្វែងរកទីផ្សារអ្នកប្រើប្រាស់ | - គាំទ្រខ្លាំងដល់អ្នកពាក់ព័ន្ធដទៃទៀត ដូចជា ជួយរកដី និងឥណទាន បង្កើតអង្គការកសិករ ។ល។<br>- ការផ្សព្វផ្សាយគំរូជោគជ័យ និងអត្ថប្រយោជន៍នៃការចូលរួមក្នុង CF<br>- ចូលរួមសកម្មក្នុងការចុះកិច្ចសន្យា និងដំណោះស្រាយវិវាទ |

កសិករ។ ទន្ទឹមនេះ សហគមន៍កសិកម្ម និងក្រុមកសិករ ដើរតួជាស្ពានរវាងសហគ្រាស និងកសិករ។ សហគមន៍កសិកម្មដើរតួនាទីសំខាន់ក្នុងការគ្រប់គ្រង ការរៀបចំកសិករ និងចែករំលែកការអនុវត្តល្អៗក្នុងចំណោមសមាជិក។ សហគមន៍កសិកម្ម ក៏គាំទ្រដល់សហគ្រាសក្នុងការត្រួតពិនិត្យស្តង់ដារគុណភាព សម្របសម្រួលកម្មវិធីប្រមូលផល ធានាការដឹកជញ្ជូនផលិតផលដែលចុះកិច្ចសន្យា និងរក្សាការមូលមតិគ្នា ក្នុងចំណោមកសិករអំពីរយៈពេលកិច្ចសន្យា។ នៅទីបញ្ចប់ ការគាំទ្ររបស់រដ្ឋាភិបាលមូលដ្ឋាន ដែលស្គាល់និងគោរពជាភាគីទី៣ក្នុងកិច្ចសន្យា រួមចំណែកយ៉ាងសំខាន់ក្នុងការផ្តួចផ្តើម និងលើកតម្កើង CF ខាងផលិតផលកសិកម្ម និងការលក់ដូរ។

លើសពីនេះ ភស្តុតាងជាក់ស្តែង បានពីការសិក្សាទាំង ៦ករណី បង្ហាញថា គំរូពហុភាគីមានសក្តានុពលជាងគេ ដើម្បីក្លាយជាគម្រោងរួមបញ្ចូលគ្នា ដើម្បីឲ្យពាក់ព័ន្ធ និងផ្តល់អត្ថប្រយោជន៍ដល់កសិករខ្នាតតូចក្នុង CF។ ប្រភេទប្រតិបត្តិការគំរូពហុភាគី គឺសមស្របតាមដំណើរការផ្លាស់ប្តូររចនាសម្ព័ន្ធកសិកម្មនៅវៀតណាម ដែលផ្តល់នូវកិច្ចសន្យា កសិករខ្នាតតូចមានឱកាសល្អ ក្នុងការទទួលបានចំណេះដឹងបច្ចេកទេស ការគាំទ្រហិរញ្ញវត្ថុ និងទីផ្សារ។

## ផលប៉ះពាល់គោលនយោបាយ

ដើម្បីសម្រួលដល់ ការអនុវត្តផលិតផលកសិកម្មតាមកិច្ចសន្យា រដ្ឋាភិបាលវៀតណាម បានចេញគោលនយោបាយគាំទ្រជាស៊េរីមួយ ដើម្បីលើកតម្កើងទំនាក់ទំនងរវាង ផលិតកម្ម និងការប្រើប្រាស់ផលិតផលកសិកម្ម (ដូចជា ក្រឹត្យ 98/2018/ND-CP) ហិរញ្ញប្បទាន សង្វាក់តម្លៃ ការធានារ៉ាប់រងកសិកម្ម និងទាក់ទាញការវិនិយោគទុនឯកជនខាងកសិកម្ម (ដូចជា ក្រឹត្យរដ្ឋាភិបាល 55/2015/ND-CP ក្រឹត្យ 116/2018/ND-CP ក្រឹត្យ 57/2018/ND-CP និងក្រឹត្យ2018/ND-CP)។ ទោះយ៉ាងណា ក្នុងដំណើរការអនុវត្តគោលនយោបាយគាំទ្រទាំងនេះ បានបង្ហាញពីកំហិតបែបបទនៃលក្ខខណ្ឌមិនអំណោយផលសម្រាប់ការចិញ្ចឹមសត្វ វារីវប្បកម្ម និងវិស័យរុក្ខាប្រម៉ាញ់ (ពីព្រោះច្បាប់ទាំងនេះ ភាគច្រើនអនុវត្តដើម្បីផលិតដំណាំ ជាពិសេសស្រូវ)។ ការអនុវត្តច្បាប់ខ្សោយ កង្វះនៃគោលការណ៍ណែនាំសម្រាប់នីតិវិធីកិច្ចសន្យា និងបទប្បញ្ញត្តិទាក់ទងនឹងយន្តការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា ជាពិសេស បទប្បញ្ញត្តិណែនាំការដោះស្រាយវិវាទ បានរាំងឧបសគ្គបន្ថែមទៀត ដល់ការទទួលយក និងទទួលបានជោគជ័យនៃការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា។

ពីលទ្ធផលផ្អែកលើភ័ស្តុតាងនៃការសិក្សាទាំង ៦ករណី និងការវិភាគគោលនយោបាយគាំទ្រដំណោះស្រាយខាងក្រោម ត្រូវបានស្នើឡើងដើម្បីលើកទឹកចិត្ត និងលើកស្ទួយប្រសិទ្ធភាពផលិតកម្មកសិកម្មតាមកិច្ចសន្យានៅប្រទេសវៀតណាម។ ទី១ បរិយាកាសជំនួញសម្រាប់សហគ្រាសកសិកម្ម គួរត្រូវកែលំអ ដើម្បីទាក់ទាញពួកគេឱ្យចូលពាក់ព័ន្ធក្នុងគំរូផលិតកម្មកសិកម្មតាមកិច្ចសន្យា។ សមត្ថភាពអង្គការកសិករ និងសហគមន៍កសិករ គួរត្រូវពង្រឹងបន្ថែមខាងអភិបាលកិច្ចការគ្រប់គ្រង និងការទទួលបានឥណទាន ដើម្បីឱ្យមានចីរភាពកិច្ចសន្យាសម្រាប់ទាំងអស់គ្នា។ លើសពីនេះ ភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន ត្រូវការទ្រទ្រង់សម្រួលដ៏សកម្មក្នុងការបង្កើត និងការអនុវត្ត CF ខាងផលិតកម្មកសិកម្ម និងទីផ្សារ។

**ឯកសារយោង** (សូមមើលនៅក្នុងអត្ថបទភាសាជាអង់គ្លេស)